# ការរៀបចំខ្លួនសម្រាប់សន្និសីទទូទៅ

នៅពេលដែលព្រះយេស៊ូវគ្រីស្ទបានយាងទៅជួបនឹងពួកសាសន៍នីហ្វៃ ទ្រង់បានអញ្ជើញពួកគេឲ្យរៀបចំគំនិតរបស់ខ្លួនដើម្បីស្ដាប់ និងយល់អំពីសារលិខិតរបស់ទ្រង់ ( សូមមើល នីហ្វៃទី៣ ១៧:៣ ) ។ សូមស្រមៃមើលថាតើបទពិសោធន៍សន្និសីទទូទៅរបស់អ្នកអាចមានលក្ខណៈបែបណាទៅប្រសិនបើអ្នកធ្វើដូចគ្នានោះ ។

១. សិក្សាធនធានខាងក្រោមនេះដោយរកមើលវិធីដែលអ្នកអាចរៀបចំខ្លួនដើម្បីទទួលសារលិខិតរបស់ព្រះអម្ចាស់នៅក្នុងសន្និសីទទូទៅ ។ អ្នកអាចគូសចំណាំពាក្យ និងឃ្លាដែលមានអត្ថន័យទាំងឡាយដែលអ្នកចាប់អារម្មណ៍ ។

   ម៉ូសាយ ២:៩; គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:៦៣

   ប្រធាន រ័សុល អិម ណិលសុន បានបង្រៀន ៖

   

   បងប្អូននឹងបន្តស្ដាប់ឮសេចក្ដីពិតចេញពីវេទិកានេះនៅថ្ងៃនេះ និងថ្ងៃស្អែក ។ សូមកត់ត្រាទុកយោបល់ណាដែលទាក់ចំណាប់អារម្មណ៍បងប្អូន និងយោបល់ណាដែលកើតមានក្នុងគំនិតរបស់បងប្អូន ហើយបន្តនៅក្នុងចិត្តរបស់បងប្អូន ។ សូមទូលដល់ព្រះអម្ចាស់ប្រកបដោយការអធិស្ឋានដើម្បីបញ្ជាក់ថាអ្វីដែលបងប្អូនបានស្ដាប់ឮគឺជាការពិត ។ ( រ័សុល អិម ណិលសុន « តើការពិតជាអ្វី ? » លីអាហូណា ខែវិច្ឆិកា ឆ្នាំ២០២២ ទំព័រ ៣០ )

   ប្រធាន ហែនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ បានបង្រៀន ៖

   

   ខ្ញុំស្គាល់ពួកអ្នកបម្រើរបស់ព្រះដែលនឹងនិយាយទៅកាន់អ្នកក្នុងអំឡុងសន្និសីទនេះ ។ ពួកលោកត្រូវបានហៅដោយព្រះដើម្បីចែកចាយសារលិខិតដល់បុត្រាបុត្រីរបស់ទ្រង់ ។ ព្រះអម្ចាស់បានមានបន្ទូលអំពីពួកលោកថា « អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ ហើយយើងពុំកែដោះសាខ្លួនឡើយ ហើយទោះជាផ្ទៃមេឃ ហើយផែនដី នឹងកន្លងបាត់ទៅក៏ដោយ គង់តែពាក្យរបស់យើងនឹងមិនកន្លងបាត់ដែរ ប៉ុន្តែពាក្យទាំងអស់នឹងបានសម្រេច ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្ដី គឺដូចតែគ្នា » [ គោលលទ្ធិ និងសេចក្ដីសញ្ញា ១:៣៨ ] ។

   អ្នកបង្ហាញការទុកចិត្តរបស់អ្នកលើព្រះនៅពេលអ្នកស្ដាប់ដោយមានបំណងដើម្បីរៀន និងប្រែចិត្ត រួចហើយអ្នកទៅ ហើយធ្វើអ្វីក៏ដោយដែលទ្រង់សុំ ។ ប្រសិនបើអ្នកទុកចិត្តលើព្រះបានល្មមគ្រប់គ្រាន់ដើម្បីស្ដាប់សារលិខិតរបស់ទ្រង់នៅគ្រប់សុន្ទរកថា បទចម្រៀង និងការអធិស្ឋាននៅក្នុងសន្និសីទនេះ នោះអ្នកនឹងរកឃើញសារលិខិតនោះ ។ ហើយប្រសិនបើអ្នកទៅហើយធ្វើនូវអ្វីដែលទ្រង់ចង់ឲ្យអ្នកធ្វើ នោះថាមពលរបស់អ្នកដើម្បីទុកចិត្តលើទ្រង់នឹងរីកលូតលាស់ឡើង ហើយពេលនោះអ្នកនឹងត្រូវបានគ្របដណ្ដប់ដោយការដឹងគុណដោយឃើញថាទ្រង់បានទុកចិត្តលើអ្នក ។ ( ហែនរី ប៊ី អាវរិង « Trust in God, Then Go and Do » *Liahona* ខែវិច្ឆិកា ឆ្នាំ២០១០ ទំព័រ ៧៣ )

   ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ដែលកាលនោះនៅក្នុងគណៈប្រធានទីមួយ បានបង្រៀន ៖

   

   ពេលអ្នករៀបចំខ្លួនសម្រាប់សន្និសីទទូទៅ ខ្ញុំសូមអញ្ជើញអ្នកឲ្យជញ្ជឹងគិតនូវសំណួរទាំងឡាយដែលអ្នកត្រូវការចម្លើយ ។ ឧទាហរណ៍អ្នកប្រហែលជាចង់ទទួលបានការដឹកនាំ និងការណែនាំពីព្រះអម្ចាស់ចំពោះទុក្ខលំបាកដែលអ្នកកំពុងតែប្រឈមមុខ ។

   ចម្លើយចំពោះការអធិស្ឋានដ៏ជាក់លាក់ណាមួយរបស់អ្នកប្រហែលជាមកដោយផ្ទាល់ចេញពីសុន្ទរកថាណាមួយ ឬពីប្រយោគណាមួយ ។ នៅពេលខ្លះចម្លើយអាចមកនៅក្នុងពាក្យសម្ដី ប្រយោគ ឬបទចម្រៀងដែលហាក់ដូចជាមិនជាប់ទាក់ទងគ្នាសោះ ។ ដួងចិត្តពោរពេញទៅដោយការដឹងគុណចំពោះពរទាំងឡាយនៅក្នុងជីវិត និងបំណងប្រាថ្នាដ៏ស្មោះស្ម័គ្រដើម្បីនឹងស្ដាប់ និងអនុវត្តតាមពាក្យសម្ដីនៃការទូន្មានដែលនឹងរៀបចំផ្លូវសម្រាប់ទទួលវិវរណៈផ្ទាល់ខ្លួន ។ ( ឌៀថើរ អេហ្វ អុជដូហ្វ « General Conference—No Ordinary Blessing » *Ensign* ខែកញ្ញា ឆ្នាំ២០១១ ទំព័រ ៤ )

២. ចេញពីអ្វីដែលអ្នកបានសិក្សា សូមធ្វើបញ្ជីមួយអំពីរបៀបដែលអ្នកអាចរៀបចំខ្លួនដើម្បីស្ដាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់នៅក្នុងសន្និសីទទូទៅ ។

៣. សូមរាយបញ្ជីនូវវិធីមួយចំនួនទៀតដែលអ្នកអាចរៀបចំខ្លួនដើម្បីស្ដាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់នៅក្នុងសន្និសីទទូទៅ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_541-1